មជ្ឈមណ្ឌលឯកសារកម្ពុជា

# ប្រាសាទបន្ទាយឆ្មារដែលទទួលរងការលួចបំផ្លាញ

**មជ្ឈមណ្ឌលឯកសារកម្ពុជាៈ ចាន់ ប្រាថ្នា**

**កែសម្រួលៈ ឆាំង យុ**

## ក) ស្ថានភាពប្រាសាទបន្ទាយឆ្មារ

ប្រាសាទបន្ទាយឆ្មារ ត្រូវបានសាងសង់ឡើងក្នុងអំឡុងដើមសតវត្សរ៍ទី១៣ ដោយព្រះបាទជ័យវរ្ម័នទី៧ ។ ប្រាសាទនេះមានគូទឹកព័ទ្ធជុំវិញ ដែលមានបណ្តោយ ៧៧០ម៉ែត្រ ទទឹង ៦៩០ម៉ែត្រ និងមុខកាត់ ៦៣ម៉ែត្រ ។ ប្រាសាទបន្ទាយឆ្មារ មានទីតាំងស្ថិតនៅក្នុងភូមិបន្ទាយឆ្មារ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដែលជាតំបន់ដាច់ស្រយាលមួយនៅភាគខាងជើងនៃប្រទេសកម្ពុជា ។ ពោលគឺស្ថិតនៅចម្ងាយប្រមាណ ៤២៥គីឡូម៉ែត្រ ពីទីក្រុងភ្នំពេញ ឬ ៥៨គីឡូម៉ែត្រ ពីទីរួមខេត្តបន្ទាយមានជ័យ ឬប្រមាណតែ ៣០គីឡូម៉ែត្រប៉ុណ្ណោះពី ច្រកបឹងត្រកួន នៅព្រំដែនខ្មែរ-ថៃ ។



ព្រះសង្ឃនិមន្តមកលេង ប្រាសាទបន្ទាយឆ្មារ នាពេលបុណ្យចូលឆ្នាំចិនក្នុងអំឡុងខែ កុម្ភៈ ឆ្នាំ២០១៥ ។

បច្ចុប្បន្ន ប្រាសាទបន្ទាយឆ្មារ មានការខូចខាតស្ទើរតែទាំងស្រុង ។ រចនាសម្ព័ន្ធប្រាសាទត្រូវបានបំផ្លាញគ្មានសល់ ។ ចាប់ពីកំពែងទីមួយដែលនៅជាប់នឹងគូទឹក រហូតដល់តួប្រាសាទទាំងមូល គឺដួលរលំគរលើគ្នាហាក់ដូចជាពំនូកថ្មដ៏ធំមួយ ។ ដើមឈើធំៗដុះពាសពេញប្រាសាទ ។ ដើមឈើតូចៗមួយចំនួនទៀត កំពុងដុះចាក់ស្រែះនៅតាមកំពូលប្រាសាទដែលនៅសេសសល់ ។ កំពូលទាំងនោះកំពុងតែប្រឈមនឹងការបាក់ធ្លាក់ជាបន្តបន្ទាប់ ។ រូបបដិមាដែលមាននៅក្នុងប្រាសាទទទួលរងការលួចប្លន់យ៉ាងដំណំ ។ ពោលគឺនៅសល់រូបចម្លាក់តិចតួចបំផុត នៅតាមជញ្ជាំងប្រាសាទ និងបំណែករូបដែលនៅកប់ក្រោមពំនូកថ្ម ។ នៅសល់ស្លាកស្នាមជាច្រើនដែលបង្ហាញថាប្រាសាទបន្ទាយឆ្មារទទួលរងការ

លួចប្លន់ និង រើកកាយយ៉ាងគ្រោតគ្រាតក្នុងទសវត្សរ៍ឆ្នាំ៨០ និង៩០ ។

បច្ចុប្បន្ន ប្រាសាទបន្ទាយឆ្មារ ត្រូវបានជួសជុលឡើងវិញជាបណ្តើរៗ ។ ប៉ុន្តែការជួសជុលនេះនៅមានទ្រង់ទ្រាយតូចនូវឡើយ ។ ដូច្នេះដំណើរការនៃការស្តារប្រាសាទនេះឡើងវិញ គឺនឹងត្រូវប្រើពេលយូរអង្វែង ។

## ១) ការកាន់កាប់ប្រាសាទបន្ទាយឆ្មារ

ចាប់ពីឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ១៩៧៩ ប្រាសាទបន្ទាយឆ្មារ ស្ថិតនៅក្រោមការកាន់កាប់ផ្តាច់មុខរបស់ខ្មែរក្រហម ។ បរិវេណនៃប្រាសាទបន្ទាយឆ្មារ ត្រូវបានប្រើប្រាស់សម្រាប់ដាំ ដំឡូង ពោត សណ្តែកល្ពៅ និងជាកន្លែងសម្រាប់ចិញ្ចាំ ទន្រ្ទានខេត្ត ធ្វើជីកំប៉ុស ។ ចំណែកនៅខាងក្នុងប្រាសាទ ខ្មែរក្រហមយកធ្វើជាកន្លែងសម្រាប់ឲ្យកងកុមារឈានមុខស្នាក់នៅ ។ ឈុំ ខោយ សព្វថ្ងៃមានអាយុ ៥៨ឆ្នាំ ហើយបច្ចុប្បន្នរស់នៅក្នុងភូមិក្បាលទន្សោង ឃុំបន្ទាយឆ្មារ បានបញ្ជាក់ថា កុមារប្រមាណ ៤០០នាក់ ត្រូវបានខ្មែរក្រហមប្រមូលឲ្យមកស្នាក់នៅក្នុងប្រាសាទបន្ទាយឆ្មារ ។ ក្នុងនោះ កុមារមួយចំនួនត្រូវធ្វើការកាប់ឆ្ការនិងការងារដាំដុះប្រចាំថ្ងៃនៅក្បែរៗប្រាសាទបន្ទាយឆ្មារ ហើយមួយចំនួនទៀតទទួលបន្ទុកដឹកជញ្ជូនសម្ភារនិងស្បៀងពីសហករណ៍យកទៅឲ្យកងចល័ត ។ ប៉ុន្តែ ពេលយប់ត្រូវមកសម្រាកជុំគ្នានៅក្នុងប្រាសាទ ។ ឈុំ ខោយ បញ្ជាក់ទៀតថា នៅក្នុងរបបខ្មែរក្រហម ប្រាសាទបន្ទាយឆ្មារ មិនទាន់មានការខូចខាតខ្លាំងដូចសព្វថ្ងៃនេះទេ ។ មានន័យថា នៅក្នុងប្រាសាទអាចប្រើប្រាស់សម្រាប់ការស្នាក់នៅបាន ។ រូបចម្លាក់ធំៗក៏ពុំមានការបាត់បង់ដែរ ។ រូបចម្លាក់ទាំងនោះមាននៅតាម ជញ្ជាំង កំពូល និង ខ្លោងទ្វារប្រាសាទ ។

ប្រាសាទបន្ទាយឆ្មារ ត្រូវបានបំផ្លាញយ៉ាងដំណំនៅក្នុងរបបខ្មែរក្រហម ។ សន សម្ភរ ហៅ ម៉ៅ (បច្ចុប្បន្នរស់នៅក្នុងភូមិបន្ទាយឆ្មារ) បញ្ជាក់ថា ក្នុងអំឡុងឆ្នាំ ១៩៧៧-១៩៧៨ ប្រាសាទបន្ទាយឆ្មារមានការស្រុតបាក់ជាបន្តបន្ទាប់ ដោយសារទឹកជន់លិច ។ ការជន់លិចនេះគឺដោយសារខ្មែរក្រហមបិទប្រព័ន្ធលូបង្ហូរទឹកចេញចូលរបស់គូទឹកប្រាសាទ ដើម្បីរក្សាទឹកទុកសម្រាប់ស្រោចស្រពដំណាំនៅក្នុងបរិវេណប្រាសាទ ។ លើសពីនេះទៀត ខ្មែរក្រហមបានគាស់យក ថ្មបាយក្រៀម យ៉ាងច្រើនសន្ធឹកសន្ធាប់ពីប្រាសាទបន្ទាយឆ្មារ ដើម្បីយកទៅធ្វើទំនប់អាងជើងគ្រោះ ។

ចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៨ ប្រាសាទបន្ទាយឆ្មារ គឺជាដំបន់ប្រទាញប្រទង់គ្នារវាង ទ័ពស្រុក (កងកម្លាំងរបស់រដ្ឋាភិបាលកម្ពុជា និង វៀតណាម) និង ទ័ពព្រៃ (ខ្មែរក្រហម និង កងកម្លាំងប៉ារ៉ា របស់សម្តេច សឺន សាន) ។ កងទ័ពទាំងពីរនេះប្រយុទ្ធគ្នាជាញឹកញាប់នៅក្បែរ និង ក្នុងបរិវេណប្រាសាទបន្ទាយឆ្មារ ។ នៅឆ្នាំ១៩៨៣ មានការប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម និងកងទ័ព ប៉ារ៉ា របស់

សម្តេច សឺន សាន នៅក្នុងប្រាសាទបន្ទាយឆ្មារ ។ ការប្រយុទ្ធគ្នានេះបានបង្ករឲ្យមានការខូចខាត ប្រាសាទបន្ទាយឆ្មារ ប៉ែកខាងកើត ។ តាមការបញ្ជាក់របស់ សន សម្ភរ កងទ័ព ប៉ុល ពត បានប្រើកាំភ្លើងបេ-៤០ បាញ់ទៅលើ ប្រាសាទបន្ទាយឆ្មារ ដែលទាហានវៀតណាមលាក់ខ្លួននៅក្នុងនោះ ។ នៅឆ្នាំ១៩៨៩ កងទ័ព ប៉ុល ពត របស់សម្តេច សឺន សាន (វរសេនាធំលេខ-២១ របស់ ធឿក ថាំ, វរសេនាធំលេខ-២២ របស់ ខូ ឈួន, និង វរសេនាធំលេខ-២៣ របស់ ថង គឿន) បានបើកការប្រយុទ្ធទ្រង់ទ្រាយធំ និងដណ្តើមកាន់កាប់បានប្រាសាទបន្ទាយឆ្មារទាំងស្រុង ។ នៅក្នុងការប្រយុទ្ធនោះ កងកម្លាំង ប៉ុល ពត បានបាញ់ឆេះរថក្រោះរបស់កងទ័ពរដ្ឋកម្ពុជាអស់មួយគ្រឿង (នៅជិតវត្ត ក្បែរច្រកចូលប្រាសាទបន្ទាយឆ្មារ) និងចាប់បានឈ្លើយសឹកចំនួន ៨៦នាក់ ។

ចាប់ពីឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩៣ តំបន់បន្ទាយឆ្មារស្ថិតនៅក្រោមការគ្រប់គ្រងផ្តាច់មុខដោយកងកម្លាំងរបស់សម្តេច សឺន សាន ។ សន សម្ភរ និងក្រុមរបស់គាត់ (មានគ្នា១០នាក់) ត្រូវបាន ឡាយ ខែក ចាត់ឲ្យមករៀបចំរដ្ឋបាលនៅតំបន់បន្ទាយឆ្មារ ។ ចាន់ វ័ន្សលក្ខិណា ទទួលបន្ទុកខាងផ្នែកយោធា ។ ទាហានមួយចំនួនត្រូវបានដាក់ឲ្យឈរជើងនៅប្រាសាទបន្ទាយឆ្មារ ។

## គ) ការលួចវត្ថុបុរាណនៅប្រាសាទបន្ទាយឆ្មារ

ប្រាសាទបន្ទាយឆ្មារទទួលរងការបំផ្លិចបំផ្លាញយ៉ាងដំណំនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ៨០ និង ៩០ ។ ការរើកកាយប្រាសាទកើតមានស្ទើរគ្រប់ទីកន្លែង ។ ស្នូរកាំភ្លើងបាញ់បង្អើលប្រជាជនមិនឲ្យចូលប្រាសាទបន្ទាយឆ្មារ កើតមានជាញឹកញាប់ ។ ប្រាសាទដួល និងធ្លាក់បាក់យ៉ាងសន្ធប់ ។ រូបចម្លាក់តូចធំដែលនៅសេសសល់ពីសម័យខ្មែរក្រហមទទួលរងការលួចប្លន់គ្មានសល់ ។ ចម្លាក់នៅតាមជញ្ជាំងប្រាសាទត្រូវបានដោះបំបែកយកជាដុំៗអស់មួយចំនួនធំ ។ ក្រៅពីប្រាសាទបន្ទាយឆ្មារ ប្រាសាទមួយចំនួនទៀតដែលនៅជិតៗគ្នានោះ ដូចជា ប្រាសាទបន្ទាយទ័ព ប្រាសាទដូនសរ ប្រាសាទតាព្រហ្ម ក៏ទទួលរងការលួចប្លន់យ៉ាងដំណំដែរ ។ អំពើទាំងនេះប្រព្រឹត្តដោយក្រុមចោរប្រដាប់អាវុធដែលកាងនៅតំបន់នោះ សហការជាមួយក្រុមឈ្មួញទុច្ចរិតរកស៊ីជួញដូរវត្ថុបុរាណនៅជាប់ព្រំដែនក្នុងប្រទេសថៃ ។ វត្ថុបុរាណទាំងនោះត្រូវបានដឹកយកចេញពីប្រាសាទដោយប្រើ គោយន្ត និង ឡានដឹកទឹក យកលក់ឲ្យឈ្មួញថៃនៅតាមច្រកបឹងត្រកួន ព្រំដែនខ្មែរ-ថៃ ។ រូបចម្លាក់មួយចំនួនធំយកទៅលក់ឲ្យឈ្មួញរកស៊ីវត្ថុបុរាណឈ្មោះ ស៊ុម ឆាយ នៅ តាប់ព្យា ប្រទេសថៃ ។ ស៊ុម ឆាយ មានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយមេក្លោងរកស៊ី និងលួចវត្ថុបុរាណនៅបន្ទាយឆ្មារ ។